00750495

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**លេខ/No: D20/4/4**

*តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

**សំណុំរឿងព្រហ្មទណ្ឌ លេខ:** ០០៣/០៧-០៩-២០០៩-អវតក/កសចស(**អបជ ០៤**)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គីមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 11 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

**កាលបរិច្ឆេទ:** ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១១

**សាធារណៈ: (សំណៅកោសលុប)**

**សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទិននឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា អន្តរជាតិ ប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យ បំពេញកិច្ចស៊ើបសួរ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣**

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. C.E.T.C.

00750496



**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ដែលបានដាក់នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ("បណ្តឹងឧទ្ធរណ៍")[១]។ អង្គបុរេជំនុំជម្រះក៏បានទទួលផងដែរនូវសំណើសុំចេញផ្សាយជាសាធារណៈនូវសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ នៅក្នុងសំណុំរឿង ០០៣ ដែលបានកោសលុប ដែលបានស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ("សំណើសុំចេញផ្សាយ")[២]។

## I. **ប្រវត្តិនីតិវិធី និង សារណា**

១. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី២") ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរសម្រាប់សំណុំរឿង ០០៣[៣]។

២. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ[៤]។

៣. នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំពន្យារពេលកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ("សំណើសុំពន្យារពេល")[៥] ដោយបានស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ពន្យារពេលកំណត់ដាក់ពាក្យសុំតាំងខ្លួនជាដើម

---

[១] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ជំទាស់នឹង "សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣", ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ D20/4/1 ("បណ្តឹងឧទ្ធរណ៍")។

[២] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា សុំចេញផ្សាយជាសាធារណៈនូវសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ នៅក្នុងសំណុំរឿង ០០៣ ដែលបានកោសលុប ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ D20/4/3 ( "សំណើសុំចេញផ្សាយ")។

[៣] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ឯកសារស្តីពី ដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួរទី២ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារលេខ D1/1។

[៤] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D13។

[៥] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំពន្យារពេលកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D15 ("សំណើសុំពន្យារពេល")។



E.C.C.C * C.E.T.C. TRIAL CHAMBER CHAMBRE PRE...

បណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះរហូតដល់ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១។ នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួរ[៦] (រួមបញ្ចូលគ្នាជា "សំណើសុំបំពេញកិច្ចស៊ើបសួរ") ដោយបានបង្ហាញនូវឯកសារបន្ថែមទៀតដែលត្រូវបានផ្ទេរពីសំណុំរឿង ០០២ ទៅសំណុំរឿង ០០៣ រួមទាំងឯកសារថ្មីៗទៀត និងបានស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម ទាក់ទិននឹងទីតាំងឧក្រិដ្ឋកម្ម ព្រឹត្តិការណ៍ឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនសង្ស័យ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

៤. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ("ដីកាសម្រេចទី១")[៧] ដោយបង្គាប់ "ឱ្យសហព្រះរាជាអាជ្ញាបំភ្លឺក្នុងរយៈពេលពីរថ្ងៃនៃថ្ងៃធ្វើការ ថាតើមុនពេលដែលដាក់សំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញាទាំងពីរបានធ្វើការសម្រេច [sic.] អំពីការផ្ទេរអំណាច ស្របតាមវិធាន ១៣ (៣) ឬថាតើសហព្រះរាជអាជ្ញាទាំងពីរបានធ្វើកំណត់ហេតុអំពីការខ្វែងយោបល់គ្នា ស្របតាមវិធាន ៧១(១) ដែរឬទេ"។ សហចៅក្រមស៊ើបអង្កេតបានបង្ហាញពីឆន្ទៈរបស់ខ្លួនដើម្បី "ទទួលបានការបញ្ជាក់ ថាតើសហព្រះរាជអាជ្ញាជាតិត្រូវបានផ្តល់ឱកាសក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ដែលមានចែងនៅក្នុងវិធាន ១៣(៣) និង វិធាន ៧១(១) ឬទេ"[៨]។

៥. សហព្រះរាជអាជ្ញាជាតិបានធ្វើការឆ្លើយតបនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ ថា "ចំពោះការខ្វែងយោបល់គ្នានៅក្នុងសំណុំរឿង ០០៣ នេះ រវាងសហព្រះរាជអាជ្ញាជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិ គឺបានធ្វើកំណត់ហេតុនៃការខ្វែងយោបល់កាលពីថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨"

---

[៦] សំណើបំពេញកិច្ចស៊ើបសួរលើកទី១ របស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D17 ( "សំណើលើកទី១ សុំបំពេញកិច្ចស៊ើបសួរ"); សំណើលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក [redacted] ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D18 ("សំណើលើកទី២ សុំបំពេញកិច្ចស៊ើបសួរ")។ សំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹង [redacted] និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D19 ("សំណើលើកទី៣ សុំបំពេញកិច្ចស៊ើបសួរ")។

[៧] ដីកាពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារលេខ D20/1 ("ដីកាសម្រេចទី១")។

[៨] ដីកាសម្រេចទី១ ទំព័រ២។

និងបានបញ្ជាក់ថា ពុំមានការផ្ទេរអំណាច ឬការធ្វើកំណត់ហេតុនៃការខ្វែងយោបល់ណាមួយត្រូវបានកត់ត្រាជាពិសេសទាក់ទិននឹងសំណើសុំពន្យារពេលកំណត់ និងសំណើសុំបំពេញកិច្ចស៊ើបសួរ ("សំណើទាំងបួន") នោះទេ[៩]។

៦. សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការឆ្លើយតបវិញនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១១ ថា សំណើទាំងបួនត្រូវបានដាក់ដោយរូបគាត់តែម្នាក់ឯងគត់ បន្ទាប់ពីបានផ្តល់ដំណឹង និងបានបញ្ជូនសំណើទាំងនេះទៅឱ្យសហព្រះរាជអាជ្ញាជាតិ ដែលសហព្រះរាជអាជ្ញាជាតិបានពោលថា គាត់នឹងមិនដាក់ការខ្វែងយោបល់គ្នា ឬការផ្ទេរអំណាចរបស់គាត់ដល់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ[១០]។ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងជាទឡ្ហីករណ៍ថា គាត់បានដំណើរការការងារ ដោយអនុលោមទៅតាមការអនុវត្តនានាដែលត្រូវបានទទួលស្គាល់កន្លងមក និងបានលើកឡើងថា ពុំចាំបាច់មានការផ្ទេរអំណាច ឬការធ្វើកំណត់ហេតុនៃការខ្វែងយោបល់ ក្នុងការដាក់សំណើដោយឯករាជ្យក្នុងសំណុំរឿង ០០៣ ទេ ដោយសារការខ្វែងយោបល់នៅបន្តមាននៅឡើយ ហើយសហព្រះរាជអាជ្ញាជាតិបានជ្រើសរើសមិនធ្វើកំណត់ហេតុនៃការខ្វែងយោបល់បន្ថែមទៀត ទាក់ទិននឹងសំណើទាំងបួននោះ[១១]។

៧. នៅថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាសម្រេចស្តីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ("ដីកាដែលត្រូវបានជំទាស់")[១២] ដោយច្រានចោលសំណើទាំងបួនដោយចាត់ទុកថាពុំមានសុពលភាពទេ ដោយផ្អែកលើមូលដ្ឋានថា វិធានផ្ទៃក្នុង "មិនបានទុកចន្លោះណាមួយសម្រាប់ឱ្យសហព្រះរាជអាជ្ញាមួយរូប អាចធ្វើកិច្ចជាលក្ខណៈបុគ្គលបានឡើយ

---

[៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិ ទៅនឹងដីកាពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ ឯកសារលេខ D20/1។

[១០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា (អន្តរជាតិ) ចំពោះដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១១, ឯកសារលេខ D20/2, កថាខណ្ឌ ១០ និង ១៤ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាសម្រេចទី១")។

[១១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាសម្រេចទី១ កថាខណ្ឌ ១៨។

[១២] ដីកាសម្រេចស្តីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣ ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D20/3 ("ដីកាដែលត្រូវបានជំទាស់")។

លើកលែងតែមានសេចក្ដីសម្រេចផ្ទេរអំណាច ដែលត្រូវបានធ្វើឡើងដោយស្របទៅតាមវិធាន ១៣ (៣) ឬកំណត់ហេតុនៃការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា ដែលធ្វើឡើងដោយស្របទៅតាមវិធាន ៧១(១)"[១៣]។

៨. នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍[១៤] ហើយនៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ គាត់បានដាក់សារណាស្ដីពីបណ្ដឹងឧទ្ធរណ៍។ ជាបញ្ហាបឋម សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា គាត់មានសិទ្ធិដាក់បណ្ដឹងឧទ្ធរណ៍តែម្នាក់ឯង តែជាការប្រុងប្រយ័ត្ន គាត់បានធ្វើកំណត់ហេតុជាផ្លូវការនូវការខ្វែងយោបល់គ្នាមួយ មុននឹងដាក់បណ្ដឹងឧទ្ធរណ៍នេះ[១៥]។ ពាក់ព័ន្ធនឹងខ្លឹមសារនៃបណ្ដឹងឧទ្ធរណ៍របស់គាត់វិញ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ដីកាដែលត្រូវបានជំទាស់គួរត្រូវបានច្រានចោល ហើយសហចៅក្រមស៊ើបអង្កេតគួរត្រូវបានបង្គាប់ឱ្យពិចារណា ទៅលើខ្លឹមសារនៃសំណើទាំងបួនដោយផ្អែកលើមូលដ្ឋានថា (១) សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងនៅពេលដែលខ្លួនបានសន្និដ្ឋានថា សំណើដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯងពុំមានសុពលភាព នីតិវិធីនៃការធ្វើកំណត់ហេតុនៃការខ្វែងយោបល់ពុំមែនជាលក្ខខណ្ឌតម្រូវទេ វាគ្រាន់តែជាជម្រើសមួយប៉ុណ្ណោះ បើតាមវិធានជាធរមាន និងការអនុវត្តកន្លងមកនៅ អ.វ.ត.ក (២) ការខ្វែងយោបល់ពីមុនពាក់ព័ន្ធនឹងការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនៅក្នុងសំណុំរឿង ០០៣ ដោយបញ្ចូលសកម្មភាពបន្តបន្ទាប់ទៀត ដែលបានធ្វើដោយសហព្រះរាជអាជ្ញាអន្តរជាតិក្នុងរឿងក្ដីនេះ (៣) ម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងនៅពេលបដិសេធសំណើទាំងនេះថា ពុំមានសុពលភាព ដោយពុំបានផ្ដល់ឱកាសឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ ដោះស្រាយនូវបញ្ហាវិការៈផ្នែកនីតិវិធី ហេតុនេះសហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណា ទៅលើគោលការណ៍ជាសារវ័ន្តដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និង (៤) និងជម្រើសមួយទៀត ការមិនបានពិចារណាទៅលើខ្លឹមសារនៅក្នុងសំណើទាំងបួននេះ បានធ្វើឱ្យសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តផ្ទុយទៅនឹង

---

[១៣] ដីកាដែលត្រូវបានជំទាស់ កថាខណ្ឌ ៥។

[១៤] សេចក្ដីជូនដំណឹងស្ដីពីការដាក់បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹង "ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើសុំពន្យារពេល និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣" អនុលោមតាមវិធាន ៧៤.២ និង ៧៥.១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D20/4។

[១៥] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ២។



E.C.C.C. • C.E.T.C. PRE-TRIAL CHAMBER • CHAMBRE PRÉLIMINAIRE

កាតព្វកិច្ចរបស់ខ្លួន ដែលត្រូវបើកកិច្ចស៊ើបសួរឱ្យបានពេញលេញ និងមិនលម្អៀង។ សំណើនេះមិនទាន់ត្រូវបានសម្រេចនៅឡើយទេ និងត្រូវដោះស្រាយនៅផ្នែកខាងក្រោមនេះ។

៩. ពុំមានចម្លើយតបណាមួយត្រូវបានដាក់ចំពោះបណ្ដឹងឧទ្ធរណ៍នេះទេ។

១០. នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើសុំចេញផ្សាយបណ្ដឹងឧទ្ធរណ៍របស់ខ្លួនដែលបានកោសលុប[១៦] ដែលត្រូវបានទទួលយកដោយអង្គបុរេជំនុំជម្រះនៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១។ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើបន្ថែមទៀតសុំចេញផ្សាយសំណើលើកទី១ សុំបំពេញកិច្ចស៊ើបសួរដែលបានកោសលុប ទៅអង្គបុរេជំនុំជម្រះ[១៧]។ សំណើនោះ នៅមិនទាន់សម្រេចនៅឡើយ ហើយនឹងត្រូវសម្រេច បន្ទាប់ពីនេះ ។

## II. សេចក្ដីសម្រេចលើសំណើសុំចេញផ្សាយ

១១. តាមរយៈសំណើសុំចេញផ្សាយរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យផ្សព្វផ្សាយជាសាធារណៈនូវសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ របស់ខ្លួនដែលបានកោសលុប ដែលបានដាក់ជូនសហចៅក្រមស៊ើបអង្កេត និងដែលត្រូវបានសហចៅក្រមស៊ើបអង្កេតចាត់ថ្នាក់ជាឯកសារសម្ងាត់។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា គាត់បានស្នើសុំទៅអង្គបុរេជំនុំជម្រះដោយសារសហចៅក្រមស៊ើបអង្កេតបដិសេធមិនព្រមដោះស្រាយបញ្ហានានា ដែលបច្ចុប្បន្នជាកម្មវត្ថុនៃការប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ[១៨]។

១២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំពីមុនថា សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១របស់គាត់គួរត្រូវបានចាត់ថ្នាក់ជាសម្ងាត់ នៅពេលគាត់ដាក់ឯកសារនេះទៅសហចៅក្រមស៊ើបអង្កេត។ ពុំមានអ្វីបង្ហាញឱ្យឃើញថា ក្រោយមកគាត់បានស្នើសុំឱ្យ

---

[១៦] សំណើសុំផ្សាយផ្នែកខ្លះនៃបណ្ដឹងឧទ្ធរណ៍ដែលបានកោសលុប របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង "ដីកាសម្រេចស្ដីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ឯកសារលេខ D20/4/2។

[១៧] សំណើសុំចេញផ្សាយ។

[១៨] សំណើសុំចេញផ្សាយ កថាខណ្ឌ៣។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

សហចៅក្រមស៊ើបអង្កេតចាត់ថ្នាក់ឯកសារនោះឡើងវិញទេ តែសំណើសុំចេញផ្សាយរបស់គាត់មានលក្ខណៈផ្ទុយពីនោះវិញ[19]។ ទោះបីជាអង្គបុរេជំនុំជម្រះអាចសម្រេចលើការចាត់ថ្នាក់ឯកសារឡើងវិញនៅពេលបានទទួលរឿងក្តីក៏ដោយ[20] តែជាគោលការណ៍ គឺស្ថាប័នតុលាការដែលឯកសារនោះត្រូវបានដាក់ឯណោះទេដែលត្រូវសម្រេចលើការចាត់ថ្នាក់ឯកសារនោះ[21]។ ដោយហេតុថាសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ត្រូវបានដាក់ និងត្រូវបានចាត់ថ្នាក់ដោយសហចៅក្រមស៊ើបអង្កេត និងដោយហេតុថា សហចៅក្រមស៊ើបអង្កេតនៅមានតួនាទីក្នុងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ នោះ អង្គបុរេជំនុំជម្រះយល់ឃើញថា នីតិវិធីដែលសមស្របសម្រាប់សហព្រះរាជអាជ្ញាអន្តរជាតិ គឺដំបូងគួរស្នើសុំទៅសហចៅក្រមស៊ើបអង្កេតឲ្យចាត់ថ្នាក់ឯកសារនោះឡើងវិញជាមុនសិន មុននឹងបញ្ជូនបញ្ហានេះមកអង្គបុរេជំនុំជម្រះ។ ហេតុនេះ សំណើសុំចេញផ្សាយនេះត្រូវបានបដិសេធចោល។

## III. ការសម្តែងមតិ និងសេចក្តីសន្និដ្ឋាននៅលើបណ្តឹងឧទ្ធរណ៍

១៣. ទោះបីមានការខិតខិតប្រឹងប្រែងយ៉ាងណាក្តី អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ដែលចាំបាច់ដើម្បីអាចចេញសេចក្តីសម្រេចមួយលើខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍នេះ ឬ លើការទទួលយកបណ្តឹងឧទ្ធរណ៍នេះទេ។ ដោយហេតុថា វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះត្រូវមានសំអាងហេតុនោះ មតិផ្សេងៗរបស់ចៅក្រមអង្គជំនុំជម្រះមានភ្ជាប់នឹងសេចក្តីពិចារណាទាំងនេះ។

១៤. ដោយសារថា អង្គបុរេជំនុំជម្រះមិនបានសម្រេចទៅលើបណ្តឹងឧទ្ធរណ៍នេះ វិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងចែងថា ដីកាដែលត្រូវបានជំទាស់នេះត្រូវបានតម្កល់ទុកជាបានការ។

---

[19] សំណើសុំចេញផ្សាយ កថាខណ្ឌ៣។

[20] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, អ.វ.ត.ក/០១/២០០៧/ វិសោធនកម្ម. ៦, ចុះថ្ងៃទី ២ ខែមីនា ឆ្នាំ ២០១១ ("សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ"), មាត្រា ៣.១៤ និង ៣.១២ មើលភ្ជាប់ជាមួយនឹងវិធាន ៧៧(២) នៃវិធានផ្ទៃក្នុង។

[21] សូមមើល មាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ។ មាត្រា ៤(ក) និង ៥(ខ) និង (ជ) ស្តីពីសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ថ្នាក់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿងត្រូវអនុម័ត, អ.វ.ត.ក/០០៤/២០០៩, ចុះថ្ងៃទី ៥ ខែមិថុនា ឆ្នាំ ២០០៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C

## IV. ការសម្រេចសេចក្តី

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសូម៖**

ច្រានចោលសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំចេញផ្សាយសំណើសុំបើកកិច្ចស៊ើបសួរលើកទី១ ក្នុងសំណុំរឿង ០០៣ ដែលបានកោសលុប។

ប្រកាសជាឯកច្ឆន្ទថា អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រមបួនរូបយ៉ាងតិច ទៅលើសេចក្តីសម្រេចស្តីពីបណ្តឹងឧទ្ធរណ៍នេះទេ។

ដោយអនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ភាគីមិនមានលទ្ធភាពប្តឹងតវ៉ាទេ។

**ភ្នំពេញ, ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១**

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **ន័យ ថុល** **Katinka LAHUIS** **ហួត វុទ្ធី**

ចៅក្រម ប្រាក់ គឹម សាន ចៅក្រម ន័យ ថុល និង ចៅក្រម ហួត វុទ្ធី សូមភ្ជាប់មតិយោបល់របស់ខ្លួន។ ចៅក្រម **Downing** និង ចៅក្រម **Lahuis** សូមភ្ជាប់មតិយោបល់របស់ខ្លួន។

# យោបល់របស់ចៅក្រម ប្រាក់ គីមសាន ចៅក្រម ន៉ិយ ថុល និងចៅក្រម ហួត វុទ្ធី

## I. សំណើសុំពន្យារកាលបរិច្ឆេទកំណត់ក្នុងការដាក់បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖

១. តាមការពិនិត្យលើ សំណើសុំពន្យារកាលបរិច្ឆេទកំណត់ក្នុងការដាក់បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿង ០០៣ គឺបាន (១)សុំពន្យាររហូតដល់ថ្ងៃទី *២៩ ខែ មិថុនា ឆ្នាំ ២០១១* ឬជាជម្រើសម្យ៉ាងទៀត (២) ទទួលស្គាល់ពីសុពលភាពនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *នៅក្រោយកាលបរិច្ឆេទកំណត់ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ រហូតដល់ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១* ហើយនិង(៣) ផ្តល់ព័ត៌មានអំពីបំណងរបស់ខ្លួនក្នុងការទទួលយកបណ្តឹង*រហូតដល់ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១* ឬយ៉ាងហោចណាស់នៅកាលបរិច្ឆេទណាមួយផ្សេងទៀត ដែលផ្តល់នៅកាលានុវត្តភាពពិតប្រាកដ ជូនដល់ជនរងគ្រោះ ដើម្បីអនុវត្តនូវសិទ្ធិនានារបស់ពួកគាត់ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក និងពិនិត្យលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងបញ្ហានេះ គឺបានដាក់នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១។ យើងយល់ឃើញថា បើគិតត្រឹមតែថ្ងៃដាក់បណ្តឹងឧទ្ធរណ៍ទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ គឺផុតថ្ងៃកំណត់ ថ្ងៃទី *២៩ ខែ មិថុនា ឆ្នាំ ២០១១* ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើឲ្យពន្យារពេលរួចទៅហើយ ហេតុដូច្នេះ មិនមានការចាំបាច់អ្វីទេ ដើម្បីឲ្យអង្គបុរេជំនុំជម្រះសម្រេចលើបញ្ហានេះ។

## II. [redacted] ក្នុងសំណុំរឿងលេខ ០០៣ ៖

២. តាមមាត្រា ៦ (៤) នៃកិច្ចព្រមព្រៀង ចែងថា "សហព្រះរាជអាជ្ញា *ត្រូវសហការគ្នា* ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយ ក្នុងការចោទប្រកាន់" និងតាមមាត្រា១៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា "រាល់ការសន្និដ្ឋានចោទប្រកាន់ជូនទៅអង្គជំនុំជម្រះវិសាមញ្ញ គឺជាការទទួលខុសត្រូវរបស់ព្រះរាជអាជ្ញាពីរនាក់ ម្នាក់ជាកម្ពុជា និងម្នាក់ទៀត ជាបរទេស ដែលហៅថា "សហព្រះរាជអាជ្ញា" ដែល*ត្រូវធ្វើការរួមគ្នា* ដើម្បីរៀបចំឯកសារ និងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ជូនតុលាការ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ដូច្នេះ ជាគោលការណ៍ គឺសហព្រះរាជអាជ្ញា *ត្រូវធ្វើការងាររួមគ្នា*។

៣. តាមវិធាន ១៣(៣)ចែងថា "វៀរលែងតែសកម្មភាពទាំងឡាយដែលត្រូវធ្វើរួមគ្នា ក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញា*អាច* ផ្ទេរអំណាចទៅឱ្យព្រះរាជអាជ្ញាណាមួយ ក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីររូប តាមរយៈសេចក្តីសម្រេចរួមគ្នា ជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យបំពេញកិច្ចតែម្នាក់ឯងបាន"។ តាមបញ្ញត្តិនេះ ចៅក្រមជាតិយល់ឃើញថា យើងត្រូវស្វែងយល់ពី "*សកម្មភាពរបស់សហព្រះរាជអាជ្ញា*" តើសកម្មភាពណាដែលត្រូវធ្វើរួមគ្នា ហើយតើសកម្មភាពណាដែលអាចធ្វើតែម្នាក់ឯង។

៤. ចំពោះ*សកម្មភាពដែលត្រូវធ្វើរួមគ្នា* គឺ វិធានផ្ទៃក្នុងមិនផ្តល់អំណាចឱ្យសហព្រះរាជអាជ្ញាណាមួយបំពេញកិច្ចតែម្នាក់ឯង នៅពេលខ្លួនបានទទួលការផ្ទេរអំណាចពីសហព្រះរាជអាជ្ញាម្នាក់ទៀតនោះទេ។ ដោយឡែក ចំពោះ *សកម្មភាពដែលអាចធ្វើតែម្នាក់ឯងវិញ* វិធាននេះផ្តល់សិទ្ធិឱ្យសហព្រះរាជអាជ្ញា ក្នុងការពិចារណាថា តើខ្លួនគួរផ្ទេរ ឬ មិនផ្ទេរសិទ្ធិអំណាចឱ្យសហព្រះរាជអាជ្ញាណាមួយជាអ្នកបំពេញកិច្ចតែម្នាក់ឯង ក្នុងនាមសហព្រះរាជអាជ្ញា(ទាំងពីរ)តែម្តង។ ការផ្ទេរសិទ្ធិអំណាចនេះ គឺដើម្បីបង្ហាញពីការឯកភាពគ្នា។ ប៉ុន្តែ បើសហព្រះរាជអាជ្ញាណាម្នាក់មិនបានផ្ទេរសិទ្ធិអំណាចនោះទេ គឺសហព្រះរាជអាជ្ញាម្នាក់ទៀតក៏មិនអាចបំពេញកិច្ចតែម្នាក់ឯង បាននោះដែរ។

៥. ការមិនបានផ្ទេរសិទ្ធិ មានន័យថា មិនមានការឯកភាពនោះទេ (ខ្វែងយោបល់គ្នា)។ ហេតុដូច្នោះ សកម្មភាពរបស់សហព្រះរាជអាជ្ញាណាម្នាក់ដែលបានបំពេញ ដោយគ្មានការយល់ព្រមពីសហ-ព្រះរាជអាជ្ញាម្ខាងទៀត ជាសកម្មភាពដែលគ្មានសុពលភាព។ ដើម្បីឱ្យសកម្មភាពមួយមានដំណើរការទៅមុខបាន លុះត្រាតែ សហព្រះរាជអាជ្ញាណាម្នាក់ ឬទាំងពីរ នាំយកករណីខ្វែងយោបល់គ្នាទៅដោះស្រាយ នៅចំពោះអង្គបុរេជំនុំជម្រះ។ ចំណុចនេះ ក៏ត្រូវបានអង្គបុរេជំនុំជម្រះ លើកនៅក្នុងសេចក្តីពិចារណារបស់ខ្លួនពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃ វិធានផ្ទៃក្នុង[១]។

[១] សេចក្តីពិចារណារបស់ខ្លួនពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃ វិធានផ្ទៃក្នុង (D1/1.3) ។

00750505



៦. **តាមវិធាន ៧១ (១)** ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាណាមួយ ឬទាំងពីរ*អាច* ធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ហើយត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែកដែលរក្សាទុកដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា។ តាមវិធាន ៧១(២) ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ សហព្រះរាជអាជ្ញាណាម្នាក់អាចនាំយកករណីខ្វែងយោបល់គ្នានេះ ទៅចំពោះមុខអង្គបុរេជំនុំជម្រះជាបន្ទាន់។

៧. បើតាមការបកស្រាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តាមសទិសន័យនៃពាក្យ “*អាច*” នៅក្នុងវិធាន ៧១ (១) នោះ គឺ ជាជម្រើសរបស់សហព្រះរាជអាជ្ញាមែន ប៉ុន្តែ បើគិតពីប្រយោជន៍ដើម្បីឱ្យសកម្មភាពណាមួយរបស់ខ្លួនអាចដំណើរការបាន ឬបើគិតពីការអនុវត្តដែលអាចធ្វើបាន គឺសហព្រះរាជអាជ្ញា ចាំបាច់ត្រូវតែធ្វើ *កំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នា* ដាក់ចូលនៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា ដើម្បីជាប្រយោជន៍សម្រាប់រាប់រយៈពេល ៣០ ថ្ងៃ ដែលបានកន្លងផុត។

៨. តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងចម្លើយតបរបស់ខ្លួន ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១១ ចំពោះដីការបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបំពេញកិច្ចស៊ើបសួរ ក្នុងសំណុំរឿង ០០៣ ដែលថា “*សំណើសុំទាំងបួនដែលខ្លួនបានដាក់នោះ គឺជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ហើយនៅតែស្ថិតនៅក្រោមការខ្វែងយោបល់គ្នាដំបូងដដែល។...។ នៅពេលជាមួយគ្នានេះដែរ មូលហេតុសមហេតុសមផលនៃនីតិវិធីស្តីពីការខ្វែងយោបល់គ្នា ដូចដែលបានសម្រេចតាមការពិចារណារបស់អង្គបុរេជំនុំជម្រះនោះ គឺថា សហព្រះរាជអាជ្ញាអន្តរជាតិអាចបន្តបំពេញកិច្ចតែម្នាក់ឯងបាន នៅពេលណាដែលការចោទប្រកាន់នោះទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទីពីរ*[២]”។ នោះ យើងសូមធ្វើការបញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិ

[២] នៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះដីការបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបំពេញកិច្ចស៊ើបសួរ ក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១១ ឯកសារ D 20/2 កថាខណ្ឌទី ១៦ ។

មិនបានយោងនូវកថាខណ្ឌណាមួយ នៃសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ឱ្យបានជាក់លាក់ទេ។

៩. ការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ថា សចស បានខកខានមិនបានគិតគូរទៅលើគោលការណ៍ជាមូលដ្ឋានដែលមានក្នុងវិធាន ២១ គឺ យើងយល់ឃើញថា *គោលការណ៍ជាសារវ័ន្តដែលត្រូវបកស្រាយដើម្បីការពារផលប្រយោជន៍ របស់ជនសង្ស័យ ជនត្រូវចោទ និងជនរងគ្រោះនោះ គឺមានបញ្ញត្តិនៅក្នុងអនុវិធាន ២១ (ក-ឃ) វិធាន ២១ នៃវិធានផ្ទៃក្នុង តែប៉ុណ្ណោះ* ហើយយើងយល់ឃើញថា នៅក្នុងអនុវិធាននេះ ពុំមានបញ្ញត្តិអំពីការបកស្រាយដែលទាក់ទងនឹងលក្ខខណ្ឌដែលសហចៅក្រមស៊ើបអង្កេតត្រូវតែគោរព ក្នុងបំពេញកិច្ចណាមួយនោះទេ។ ហេតុដូច្នេះ យើងយល់ឃើញថា ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមិនបានរំលោភ ទៅលើគោលការណ៍ជាសារវ័ន្តដែលមាននៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនោះទេ។

១០. លើសពីនេះទៅទៀត យោងតាមកថាខណ្ឌទី ១៣ នៃសារណានៃបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់នឹង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ដែលថា "ក្រោយពេលបានទទួលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបសួរ ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០១១ រួចហើយ សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើកំណត់ហេតុតាមទម្រង់ស្តីពីការខ្វែងយោបល់គ្នា ជាមួយនឹងសហព្រះរាជអាជ្ញាជាតិ ពាក់ព័ន្ធនឹងការស្នើសុំពន្យារពេលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនីមួយៗ។...។" និងកថាខណ្ឌទី ១៤ នៃសារណាដដែលនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ថា "ជាជម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញាអន្តរជាតិសូមជូនសេចក្តីសន្និដ្ឋានថា ៖ (ក) ទាក់ទងទៅនឹងវិធាន ២១.ក នៃវិធានផ្ទៃក្នុង លក្ខខណ្ឌតម្រូវដែលថាដំណើរការនីតិវិធី (រក្សានូវតុល្យភាពមួយរវាងភាគីនានា) សចស គួរតែផ្តល់ដល់សហព្រះរាជអាជ្ញាអន្តរជាតិ នូវកាលានុវត្តភាពមួយដើម្បីដោះស្រាយនូវកំហុសនីតិវិធីដែលបានយល់ឃើញ។" នោះបង្ហាញថា សហព្រះរាជអាជ្ញាអន្តរជាតិក៏ទទួលស្គាល់ថា ខ្លួនពិតជាមានកំហុសនីតិវិធី ដោយមិនគោរពទៅតាមលក្ខខណ្ឌទំរង់នៃនីតិវិធី ដែលជាមូលហេតុនាំឱ្យសហចៅក្រមស៊ើបអង្កេត ច្រានចោលនូវសំណើរបស់ខ្លួន។

*យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី*

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉ...

១១. សំណើសុំឲ្យធ្វើការស៊ើបសួរបន្ថែម ថ្វីត្បិតមិនមែន ជាប្រភេទដីកាដូចជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ក៏ដោយ ប៉ុន្តែ វាជាប្រភេទសំណើសុំឲ្យបំពេញ កិច្ចស៊ើបសួរ ដែលមានវិសាលភាពធំធេង ហើយខ្លឹមសារនៃសំណើនោះ គឺមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី២ និងទី៣ ហើយកន្លងមក សហព្រះរាជអាជ្ញាជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិខ្វែងគំនិតគ្នាលើ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ២ និង ទី៣ ដែលមានអង្គហេតុ ដូចគ្នានឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយបានធ្វើកំណត់ហេតុខ្វែងគំនិតគ្នាដាក់ជូនអង្គបុរេជំនុំជម្រះធ្វើការពិចារណាសម្រេចសេចក្តី ដូច្នេះការធ្វើកំណត់ហេតុខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា គឺជាការខានពុំបាន ហើយការគោរពថេរវេលា ៣០ ថ្ងៃ កន្លងផុតត្រូវតែគោរព។

១២. ហេតុដូច្នេះយើងយល់ឃើញថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតបដិសេធនូវសំណើសុំពន្យារពេលកំណត់សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទី១ សំណើលើកទី២ និងសំណើបំពេញកិច្ចស៊ើបសួរលើកទី៣ ក្នុងសំណុំរឿងលេខ ០០៣ ដោយសំអាងថា គ្មានសុពលភាព ដោយសារគ្មានការផ្ទេរអំណាច ឬគ្មានកំណត់ហេតុនៃការខ្វែងយោបល់គ្នា នោះ ជាការត្រឹមត្រូវ។

ភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១១

ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល ចៅក្រម ហួត វុទ្ធី

## មតិយោបល់របស់ចៅក្រម LAHUIS និង ចៅក្រម DOWNING

១. ដូចមានសំអាងហេតុពន្យល់នៅក្នុងចំណុចខាងក្រោម យើងយល់ឃើញថា សំណើទាំងនេះត្រូវបានដាក់យ៉ាងត្រឹមត្រូវ ដោយសហព្រះរាជអាជ្ញាអន្តរជាតិតែម្នាក់ឯង។ ដូច្នេះ យើងយល់ឃើញថា ដីកាដែលត្រូវបានជំទាស់ គួរត្រូវច្រានចោល ហើយបញ្ហានេះគួរត្រូវបង្វិលត្រឡប់ឱ្យទៅសហចៅក្រមស៊ើបអង្កេត ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចលើអង្គសេចក្តីនៃសំណើទាំង ៤ នេះឡើងវិញ។ ដោយហេតុថា ការពិភាក្សារបស់យើងលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះ នឹងមានអានុភាពចំពោះមតិយោបល់របស់យើងស្តីពីភាពអាចទទួលយកបាន ដូច្នេះ ជាបឋម យើងនឹងបង្ហាញមតិយោបល់របស់យើងលើភាពអាចទទួលយកបាននេះជាមុនសិន មុននឹងលើកឡើងអំពីអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍។

### I- ខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍៖

២. ពីដំបូង យើងពិចារណាឃើញថា ជាគោលការណ៍ វិធានផ្ទៃក្នុងផ្តល់លទ្ធភាពឱ្យសហព្រះរាជអាជ្ញាណាម្នាក់ក្នុងចំណោមសហព្រះរាជអាជ្ញទាំង ២ អាចបំពេញកិច្ចតែម្នាក់ឯងបាន។ នៅក្នុងន័យនេះ វិធាន ១(២) នៃវិធានផ្ទៃក្នុង ចែងនៅត្រង់ផ្នែកដែលពាក់ព័ន្ធថា "ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះចំពោះពាក្យសហព្រះរាជអាជ្ញា សំដៅទៅដល់សហព្រះរាជអាជ្ញាទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា *និងសហព្រះរាជអាជ្ញាណាម្នាក់ក្នុងចំណោមអ្នកទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង* ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ" (គូសបញ្ជាក់បន្ថែម)។ វិធាន ១៣ នៃវិធានផ្ទៃក្នុងដែលបើកលទ្ធភាពឱ្យសហព្រះរាជអាជ្ញាធ្វើប្រតិភូកម្មអំណាច[១] បានបញ្ញត្តិបន្ថែមទៀតថា "ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា នីតិវិធីដែលមានចែងក្នុងវិធាន ៧១ ត្រូវយកមកអនុវត្ត"។ វិធាននេះចែងច្បាស់ថា យោងតាមអត្ថន័យនៃវិធាន ១(២) នៃវិធានផ្ទៃក្នុងសហព្រះរាជអាជ្ញាណាម្នាក់ អាចបំពេញកិច្ចតែម្នាក់ឯង "ដោយផ្ទាល់" បាន ប្រសិនបើសហព្រះរាជអាជ្ញានោះ គោរពទៅតាមវិធាននានា ដែលអនុវត្តជាធរមានចំពោះការខ្វែងយោបល់គ្នា។ ការបក

---

[១] វិធាន ១៣(៣) នៃវិធានផ្ទៃក្នុងចែងថា៖ "វៀរលែងតែសកម្មភាពទាំងឡាយដែលត្រូវធ្វើរួមគ្នា ក្រោមច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងវិធានផ្ទៃក្នុងនេះ សហព្រះរាជអាជ្ញាអាចផ្ទេរអំណាចទៅឱ្យព្រះរាជអាជ្ញាណាមួយក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីររូប តាមរយៈសេចក្តីសម្រេចរួមគ្នាជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យបំពេញកិច្ចតែម្នាក់ឯងបាន"។

ស្រាយបែបនេះ មានលក្ខណៈស៊ីសង្វាក់គ្នាទៅនឹងយុត្តិសាស្ត្រមុនៗរបស់អង្គបុរេជំនុំជម្រះ[២]។ ដូច្នេះ បញ្ហាចម្បងដែលត្រូវយកមកសម្រេចនោះគឺថាតើលក្ខខណ្ឌកំណត់នៅក្នុងវិធានផ្ទៃក្នុងអនុញ្ញាត ឬ ពុំអនុញ្ញាតឱ្យសហព្រះរាជអាជ្ញា អាចបំពេញកិច្ចតែម្នាក់ឯងដែរឬទេ នៅពេលសហព្រះរាជអាជ្ញាម្នាក់ទៀត ពុំឯកភាពលើចំណាត់ការដែលបានស្នើឡើង និងថាតើការមិនគោរពតាមលក្ខខណ្ឌទាំងនេះ អាច ឬ ពុំអាចមានផលវិបាកចំពោះសុពលភាពនៃកិច្ចដែលបានធ្វើតែម្នាក់ឯង។

៣. យើងសង្កេតឃើញថា វិធានផ្ទៃក្នុងបង្កើតនូវនីតិវិធីសម្រាប់ដោះស្រាយស្ថានភាពទាំងឡាយណាដែលសហព្រះរាជអាជ្ញា មានការខ្វែងយោបល់គ្នា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ពាក់ព័ន្ធនឹងការកាត់សេចក្ដីក្រោមច្បាប់កម្ពុជា លើឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង") (មាត្រា ៦(៤) និង ៧)[៣] និងច្បាប់ស្ដីអំពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក") (មាត្រា ២០ (ថ្មី))[៤]។ វិធានផ្ទៃក្នុងចង្អុលបញ្ជាក់ថា

---

[២] នៅពេលពិចារណាលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះ បានរកឃើញនៅក្នុងកថាខណ្ឌ ១៦ នៅក្នុងផ្នែករួមនៃការពិចារណារបស់ខ្លួន ថា "មាត្រា ៦(១) និង(៤) នៃកិច្ចព្រមព្រៀង មាត្រា ១៦ និង២០(ថ្មី) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងវិធាន ៧១(៣) នៃវិធានផ្ទៃក្នុង បញ្ជាក់យ៉ាងច្បាស់ថា សហព្រះរាជអាជ្ញា អាចបំពេញកិច្ចតែម្នាក់ឯងបាន ដោយពុំចាំបាច់ការយល់ព្រមពីសហព្រះរាជអាជ្ញាម្នាក់ទៀតទេ ប្រសិនបើពុំមានសហព្រះរាជអាជ្ញាណាម្នាក់ បានដាក់ការខ្វែងយោបល់គ្នានេះ នៅចំពោះមុខអង្គបុរេជំនុំជម្រះ ក្នុងរយៈពេលកំណត់ជាក់លាក់មួយនោះ" ការខ្វែងយោបល់គ្នាលេខ ០០១/១៨-១១-២០០៨ អ.វ.ត.ក/អបជ សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ("សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះលើការខ្វែងយោបល់គ្នា")៖

[៣] មាត្រា ៦(៤) នៃកិច្ចព្រមព្រៀងចែងថា៖ "សហព្រះរាជអាជ្ញាត្រូវសហការគ្នា ដើម្បីឈានទៅដល់ការឯកភាពគ្នាមួយ ក្នុងការចោទប្រកាន់។ ក្នុងករណីដែលព្រះរាជអាជ្ញាមិនអាចឯកភាពគ្នាថា ត្រូវបន្តការចោទប្រកាន់ណាមួយ ការចោទប្រកាន់នោះត្រូវដំណើរការទៅមុខទៀត លើកលែងតែសហព្រះរាជអាជ្ញាទាំងពីរនេះ ឬ ព្រះរាជអាជ្ញាណាមួយក្នុងចំណោមព្រះរាជអាជ្ញាទាំងពីរធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃឱ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧"។

[៤] មាត្រា ២០ (ថ្មី) នៃច្បាប់ស្ដីអំពីការបង្កើត អ.វ.ត.ក ចែងនៅត្រង់ផ្នែកដែលពាក់ព័ន្ធថា៖

> "ក្នុងករណីដែលមានភាពខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ត្រូវអនុវត្តគោលការណ៍ដូចខាងក្រោម៖ ការចោទប្រកាន់ត្រូវបន្ត ដរាបណាសហព្រះរាជអាជ្ញា ឬក៏សហព្រះរាជអាជ្ញាម្នាក់ពុំបានស្នើក្នុងរយៈពេលសាមសិបថ្ងៃថា ភាពខ្វែងយោបល់គ្នាត្រូវបានដោះស្រាយ ដោយអនុលោមតាមបទប្បញ្ញត្តិដូចខាងក្រោម៖

ការប្រើប្រាស់នីតិវិធីសម្រាប់ការដោះស្រាយការខ្វែងយោបល់គ្នា គឺជាគោលការណ៍ជម្រើស ពុំមែនជាគោលការណ៍ចាប់បង្ខំនោះទេ។ និយាយម៉្យាងទៀត វាជាបញ្ហាឆន្ទានុសិទ្ធិរបស់សហព្រះរាជអាជ្ញាណាម្នាក់ ឬ សហព្រះរាជអាជ្ញាទាំងពីរ ក្នុងការប្រើប្រាស់នីតិវិធីស្តីពីការខ្វែងយោបល់គ្នានេះ និងក្នុងការធ្វើចំណាត់ការលើបញ្ហានេះ ទៅត្រឹមកម្រិតណាដែលខ្លួនចង់បាន។ នៅក្នុងន័យនេះ វិធាន ៧១(១)នៃវិធានផ្ទៃក្នុងចែងថា "ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញាណាមួយ ឬ ទាំងពីរ*អាច*ធ្វើកំណត់ហេតុអំពីមូលហេតុពិតប្រាកដនៃការខ្វែងយោបល់គ្នានេះដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ហើយត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយឡែក ដែលរក្សាទុកដោយក្រឡាបញ្ជីនៃការិយាល័យសហ-ព្រះរាជអាជ្ញា" (គូសបញ្ជាក់បន្ថែម)។ នៅពេលប្រើប្រាស់ពាក្យថា "អាច" ពាក្យនេះគឺផ្តល់ជាឆន្ទានុសិទ្ធិលើការធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នា ដោយពុំបង្កើតជាកាតព្វកិច្ចចាំបាច់ត្រូវតែធ្វើកំណត់ហេតុឡើយ។ កថាខណ្ឌ ២ នៃវិធានដដែលនេះបញ្ញត្តិបន្ថែមទៀត "ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ សហព្រះរាជអាជ្ញាណាម្នាក់ *អាច*នាំយកករណីខ្វែងយោបល់គ្នានេះទៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈការបញ្ជូនឯកសារអំណះអំណាងជាលាយលក្ខណ៍អក្សរអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់គ្នា" (គូសបញ្ជាក់បន្ថែម)។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាមានឆន្ទានុសិទ្ធិក្នុងការនាំ ឬ ពុំនាំយកការខ្វែងយោបល់គ្នាទៅចំពោះមុខអង្គបុរេជំនុំជម្រះ ដោយ

---

សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីអង្គហេតុ និងហេតុផលទាំងឡាយចំពោះ គោលជំហរខុសគ្នារបស់គេ ដល់ប្រធានការិយាល័យរដ្ឋបាល។

ភាពខ្វែងយោបល់គ្នាត្រូវតែដោះស្រាយភ្លាម ដោយអង្គបុរេជំនុំជម្រះដែលមានចៅក្រមប្រាំរូប ចៅក្រមខ្មែរបីរូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានចៅក្រមមួយរូបជាប្រធាន ហើយនិងចៅក្រមបរទេសពីររូប ត្រូវបានជ្រើសតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បន្ទាប់ពីមានការជ្រើសរើសឲ្យឈរឈ្មោះ ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការជ្រើសរើសចៅក្រមខាងលើនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១០ ថ្មី នៃច្បាប់នេះ។

បន្ទាប់ពីទទួលបានកំណត់ហេតុដូចដែលមានចែងនៅក្នុងកថាខណ្ឌទី៣ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះជាបន្ទាន់ ហើយត្រូវជូនដំណឹងអំពីកំណត់ហេតុដល់សមាជិកអង្គបុរេជំនុំជម្រះ។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលពុំបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍ តម្រូវឲ្យមានសំឡេងវិជ្ជមានពីចៅក្រម បួនរូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់ប្រធានការិយាល័យរដ្ឋបាល ដែលត្រូវផ្សព្វផ្សាយសេចក្តីសម្រេចនេះ ហើយជូនដំណឹងដល់សហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញាត្រូវចាត់ការបន្តជាបន្ទាន់ដោយអនុវត្តតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ ប្រសិនបើពុំមានមតិភាគច្រើន ដូចតម្រូវឲ្យមានចំពោះការធ្វើសេចក្តីសម្រេចទេ ការចោទប្រកាន់ត្រូវធ្វើបន្តទៅទៀត"។

វិធាននេះពុំបង្កើតជាកាតព្វកិច្ចចាំបាច់ឡើយ ដូចអង្គបុរេជំនុំជម្រះបានលើកឡើងនាពេលមុន[៥]។

៤. ការធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នា គឺមានគោលបំណងដើម្បីបង្ហាញភស្តុតាងអំពីកាលបរិច្ឆេទនៃការចុះក្នុងសំណុំឯកសារ អំពីលក្ខណៈជាក់លាក់នៃការខ្វែងយោបល់គ្នា ព្រមទាំងដើម្បីបង្ហាញជាភស្តុតាងថា ការខ្វែងយោបល់គ្នា ត្រូវបានចាត់ទុកថា មានលក្ខណៈអាចទំនងឈានទៅដល់យន្តការដោះស្រាយវិវាទជាផ្លូវការមួយ។ ការបង្ហាញភស្តុតាងនូវកាលបរិច្ឆេទនៃការចុះក្នុងសំណុំឯកសារ គឺជាលក្ខខណ្ឌតម្រូវមួយ ដោយហេតុថា វិធានការផ្លូវការបន្ទាប់មកទៀតក្នុងការដាក់ការខ្វែងយោបល់គ្នានៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមរយៈការិយាល័យរដ្ឋបាល គឺកម្រិតត្រឹមរយៈពេល ៣០ ថ្ងៃ ក្រោយពីបានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នា។ បន្ទាប់ពីរយៈពេលនេះទៅ សិទ្ធិដាក់ការខ្វែងយោបល់គ្នា នឹងបញ្ចប់ ហើយការខ្វែងយោបល់គ្នាត្រូវបានចាត់ទុកថាបានផុតរលត់។ ដូច្នេះ វាគ្មានហេតុផលណាមួយ ឬ វាគ្មានអានុភាពអ្វីចាំបាច់ចាប់បង្ខំសហព្រះរាជអាជ្ញា ឲ្យធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នានេះឡើយ ប្រសិនបើសហព្រះរាជអាជ្ញាណាម្នាក់ពុំមានបំណងបន្តចាត់ការបញ្ហានេះទេនោះ។

៥. នៅពេលវាយតម្លៃលើសុពលភាពនៃការដាក់សំណើទាំង ៤ យើងពិចារណាឃើញទៀតថា ការធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នា នឹងពុំមានអានុភាពប៉ះពាល់ដល់សិទ្ធិរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការដាក់សំណើទាំង ៤ តែម្នាក់ឯងនោះទេ។ ក្នុងករណីមានការចុះក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា និងក្នុងអំឡុងពេលនៃការដោះស្រាយវិវាទនេះ វិធានផ្ទៃក្នុងចែងយ៉ាងច្បាស់ថា កិច្ចណាដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នា ជាទូទៅ ត្រូវតែនៅអនុវត្តដដែល[៦]។ ករណីលើកលែង ដែលបានកំណត់នៅក្នុងវិធានផ្ទៃក្នុង គឺមានតែចំពោះបញ្ហាចម្បងៗពាក់ព័ន្ធនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលពាក់ព័ន្ធនឹងបទល្មើសថ្មី ដីកាសន្និដ្ឋានស្ថាពរ ឬ សេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ[៧]។ លុះណាតែកិច្ចទាំងនេះជាកម្មវត្ថុនៃការខ្វែងយោបល់គ្នា ត្រូវបានធ្វើកំណត់ហេតុ វិធានផ្ទៃក្នុងចែងថា គ្មានសកម្មភាពត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាណាមួយត្រូវបានសម្រេចឡើង ឬ រយៈពេល ៣០ ថ្ងៃ ត្រូវបានកន្លងផុត ឬ អង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែង

[៥] សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើការខ្វែងយោបល់គ្នា កថាខណ្ឌ ១៦។

[៦] វិធាន ៧១(៣) នៃវិធានផ្ទៃក្នុង។ មាត្រា ៦(៤) នៃកិច្ចព្រមព្រៀង។ មាត្រា ២០ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[៧] វិធាន ៧១(៣) នៃវិធានផ្ទៃក្នុង។

យោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ។ យោងតាមប្រព័ន្ធនេះ គ្រប់ករណីទាំងអស់ផ្សេងទៀត លើកលែងតែអញ្ញត្រកម្មដូចបានលើកឡើងខាងលើ កិច្ចណាមួយដែលបានបំពេញដោយសហព្រះរាជអាជ្ញាណាម្នាក់ នឹងនៅតែមានអានុភាពបន្តទៅមុខ លុះណាតែអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចបញ្ចប់អានុភាពនោះ។ ហេតុដូច្នេះ ទោះបីជាក្នុងករណីការខ្វែងយោបល់គ្នាត្រូវបានធ្វើកំណត់ហេតុ ហើយដាក់ជូនទៅចំពោះមុខអង្គបុរេជំនុំជម្រះក៏ដោយក្តី ជាទូទៅ ការធ្វើកំណត់ហេតុ និងការដាក់ជូនទៅចំពោះមុខអង្គបុរេជំនុំជម្រះនេះ ពុំមានអានុភាពរារាំងមិនឲ្យកិច្ចរបស់សហព្រះរាជអាជ្ញាបន្តទៅមុខនោះឡើយ។

៦. ជាចុងក្រោយ យើងកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា ខ្លួនតែងតែបង្ហាញសេចក្តីសន្និដ្ឋានរបស់ខ្លួនជូនទៅសហព្រះរាជអាជ្ញាជាតិ ដើម្បីផ្តល់លទ្ធភាពឲ្យសហព្រះរាជអាជ្ញាជាតិ បង្កើតនូវមតិយោបល់ណាមួយលើបញ្ហានេះ មុនពេលដាក់សំណើ។ យើងយល់ឃើញថា ការបង្ហាញដូច្នេះ គ្រប់គ្រាន់អាចឲ្យសហព្រះរាជអាជ្ញាជាតិ មានលទ្ធភាពអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងការជំរុញឲ្យមានយន្តការដោះស្រាយវិវាទជាផ្លូវការ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង។ លើសពីនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានសន្និដ្ឋាននៅក្នុងបណ្តឹងឧទ្ធរណ៍ថា នៅក្នុងរឿងក្តីនេះ សហព្រះរាជអាជ្ញាជាតិបានលើកឡើងថា ខ្លួននឹងមិនដាក់ការខ្វែងយោបល់គ្នា មុនពេលសហព្រះរាជអាជ្ញាអន្តរជាតិដាក់សំណើទាំង ៤ នោះទេ។ ដូច្នេះ យើងអាចចាត់ទុកថា សហព្រះរាជអាជ្ញាជាតិបានបោះបង់សិទ្ធិក្នុងការប្រើប្រាស់យន្តការដោះស្រាយវិវាទជាផ្លូវការនេះរួចទៅហើយ។

៧. យោងតាមហេតុផលទាំងនេះ យើងយល់ឃើញថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដែលត្រូវបានជំទាស់ ពុំស្របគ្នាទៅនឹងបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុងឡើយ ដោយហេតុថាសហចៅក្រមស៊ើបអង្កេតបានសម្រេចដោយភ័ន្តច្រឡំថា ការដែលមិនបានធ្វើកំណត់ហេតុនៃការខ្វែងយោបល់គ្នានៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា មានអានុភាពនាំឲ្យសហចៅក្រមស៊ើបអង្កេតសន្និដ្ឋានថា កិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពុំមានសុពលភាពឡើយ។ ផ្ទុយមកវិញ យើងយល់ឃើញថា ប្រសិនបើការខ្វែងយោបល់គ្នាពុំបានធ្វើកំណត់ហេតុទេនោះ កិច្ចដែលបានធ្វើឡើងនោះ អាចនៅតែបន្តជាកិច្ចមានសុពលភាពដដែល។ ប្រសិនបើសហព្រះរាជអាជ្ញាណាម្នាក់ក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីរ ពុំឯកភាពនឹងចំណាត់ការជាក់លាក់ណាមួយ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញាម្នាក់ទៀតនោះ និងប្រសិនបើការខ្វែងយោបល់គ្នាពុំបានធ្វើកំណត់

ហេតុជាផ្លូវការនោះទេ យើងត្រូវសន្និដ្ឋានថា ការខ្វែងយោបល់គ្នានោះមិនចាត់ទុកថាចាំបាច់ត្រូវយកមកដោះស្រាយជាផ្លូវការឡើយ។ ហេតុដូច្នេះ យើងពិចារណាឃើញថា សំណើទាំង ៤ បានដាក់យ៉ាងត្រឹមត្រូវដោយសហព្រះរាជអាជ្ញាអន្តរជាតិ ហើយអង្គបុរេជំនុំជម្រះ គួរបង្វិលបញ្ហានេះត្រឡប់ឲ្យទៅសហចៅក្រមស៊ើបអង្កេត សម្រេចឡើងវិញ។

៨. ដោយហេតុមតិយោបល់របស់យើងបង្ហាញថា បទប្បញ្ញត្តិគតិយុត្តជាធរមាន បានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអន្តរជាតិ បំពេញកិច្ចតែម្នាក់ឯងបាន យើងអាចចោទសួរបន្ថែមទៀតថាតើសហចៅក្រមស៊ើបអង្កេត មានសិទ្ធិសួរទៅសហព្រះរាជអាជ្ញាអំពីសាវតាកើតឡើងជុំវិញការដាក់ឯកសាររបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះដែរឬទេ ពីព្រោះតែសាវតាគតិយុត្ត ដែលបានលើកឡើងដោយសហចៅក្រមស៊ើបអង្កេត មានលក្ខណៈប្រហាក់ប្រហែលនឹងសាវតាគតិយុត្ត ដែលបានរៀបរាប់នៅក្នុងដីកាដែលត្រូវបានជំទាស់[៨]។ យើងយល់ឃើញថា បញ្ហាស្តីពីរបៀបនៃការបំពេញកិច្ចរួមគ្នារវាងសហព្រះរាជអាជ្ញាទាំងពីរ គឺជាបញ្ហាផ្ទៃក្នុង នៅក្នុងការិយាល័យឯករាជ្យរបស់សហព្រះរាជអាជ្ញា។ អាស្រ័យហេតុនេះ ការខ្វែងយោបល់គ្នាបានធ្វើកំណត់ហេតុនៅក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា ដែលជាសំណុំឯកសារផ្ទៃក្នុងរបស់ការិយាល័យសហព្រះរាជអាជ្ញា ហើយត្រូវបានរក្សាការសម្ងាត់[៩]។ ពីព្រោះតែពុំមានការលើកឡើងបញ្ហាណាមួយផ្ទុយពីករណីនេះ បុគ្គលនៅក្រៅ អាចរំពឹងទុកថា សហព្រះរាជអាជ្ញាទាំងពីរ បានបំពេញកិច្ចនេះរួមគ្នា ហេតុដូច្នេះ សហព្រះរាជអាជ្ញាទាំងពីរត្រូវបានសន្មតថាបានដឹងអំពីកិច្ច ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញាម្នាក់ទៀត។ ក្នុងករណីចាំបាច់ សហព្រះរាជអាជ្ញាទាំងពីរ មានសមត្ថភាពបង្ហាញឲ្យបានច្បាស់ និងជាផ្លូវការ អំពីការខ្វែងយោបល់គ្នាលើចំណាត់ការដែលបានស្នើឡើង ឬ ដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញាណាម្នាក់។ ប្រសិនបើករណីនេះកើតឡើងដូច្នេះមែន បទប្បញ្ញត្តិស្តីពីដំណោះស្រាយលើការខ្វែងយោបល់គ្នា ផ្តល់ជាយន្តការផ្លូវការមួយ ដែលសហព្រះរាជអាជ្ញាទាំងពីរ ឬ សហព្រះរាជអាជ្ញាណាម្នាក់ អាចជ្រើសរើសបទប្បញ្ញត្តិនេះ យកមកអនុវត្តបាន។ វាពុំមែនជាតួនាទីរបស់សហចៅក្រមស៊ើបអង្កេត ឬ ស្ថាប័នណាផ្សេង ដែលត្រូវមានភារៈត្រួតពិនិត្យលើការិយាល័យសហព្រះរាជអាជ្ញាឡើយ។ សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា កាលពីលើកមុន និង នាពេលក្រោយៗមក សហព្រះរាជអាជ្ញាបានចុះក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នា ហើយនាំការខ្វែងយោបល់គ្នាទៅចំពោះមុខអង្គបុរេជំនុំជម្រះ អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿង

[៨] ដីកាសម្រេចទី១ ទំព័រ ២។

[៩] វិធាន ៧១(១) នៃវិធានផ្ទៃក្នុង។

00750514



ឱ្យស៊ើបសួរនៅក្នុងសំណុំរឿង ០០៣។ ទោះក្នុងករណីណាក៏ដោយ ការទទួលស្គាល់នេះបង្ហាញថា សហព្រះរាជអាជ្ញាទាំងពីរបានដឹងយ៉ាងច្បាស់អំពីលក្ខណៈនៃវិធាន ៧១ នៃវិធានផ្ទៃក្នុង ព្រមទាំងបានដឹងយ៉ាងច្បាស់ថា វិធាននេះអនុវត្តដោយរបៀបណា។

៩. លើសពីនេះទៀត ក្រោយពីពិចារណាលើសំអាងហេតុ និងសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត យើងយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានបដិសេធសំណើទាំងនេះថាពុំមានសុពលភាព ដោយសារកំហុសនីតិវិធី (ពោលគឺ ពុំមានការចុះក្នុងកំណត់ហេតុនៃការខ្វែងយោបល់គ្នា)។ យើងពិចារណាថា សេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបដិសេធសំណើទាំងនេះថាពុំមានសុពលភាព ដោយផ្អែកលើមូលដ្ឋាននៃវិការៈលើទម្រង់បែបបទ (ដែលយើងយល់ឃើញថា ពុំអាចយកមកសម្រេចបដិសេធដោយរបៀបនេះចំពោះសហព្រះរាជអាជ្ញាអន្តរជាតិឡើយ) គឺពុំមានភាពសមហេតុផលឡើយ នៅក្នុងកាលៈទេសៈបច្ចុប្បន្នដែល i) សហចៅក្រមស៊ើបអង្កេតបានដឹងថា សហព្រះរាជអាជ្ញាជាតិ ពុំចង់ខ្វែងយោបល់គ្នាលើការដាក់សំណើទាំងនេះជាផ្លូវការ ii) សហព្រះរាជអាជ្ញាជាតិ ពុំបានលើកឡើងថា ខ្លួនទទួលរងគ្រោះពីការដាក់ការខ្វែងយោបល់គ្នា iii) កំហុសនីតិវិធី អាចត្រូវបានដោះស្រាយដោយសហព្រះរាជអាជ្ញាអន្តរជាតិដោយងាយស្រួល និង iv) សារៈសំខាន់នៃការត្រូវតែដាក់សំណើនេះ និងផលវិបាកចំពោះការមិនដោះស្រាយលើអង្គសេចក្ដីនៃសំណើទាំងនេះ។

១០. ជាពិសេស យើងកត់សម្គាល់ឃើញថា ទោះបីជាវិធានផ្ទៃក្នុងមិនបានចែងដោយផ្ទាល់អំពីបញ្ហាជាក់លាក់នេះក៏ដោយ ក៏វិធានផ្ទៃក្នុងនេះបានចែងទុកថា កំហុសនីតិវិធីនឹងមិនបណ្ដាលឱ្យមានការចាត់ទុកកិច្ចដែលត្រូវបានជំទាស់ ជាមោឃៈឡើយ។ ព្យសនកម្ម ដែលបានប៉ះពាល់ដល់ភាគី ត្រូវតែយកមកពិចារណា ហើយភាគីអាចថែមទាំងមានសិទ្ធិបោះបង់ចោលសិទ្ធិស្នើសុំមោឃៈភាពបាន និងដែលនាំឱ្យមាននិយ័តភាពលើកកិច្ចដំណើរការនីតិវិធី[១០]។ ពាក់ព័ន្ធនឹងការអនុវត្តអន្តរជាតិវិញ យើងកត់សម្គាល់ឃើញថា តុលាការយុត្តិធម៌អន្តរជាតិ ("ត.យ.អ") បានពិចារណាយ៉ាងស្របគ្នាថា ខ្លួន "មិនគួរដាក់ទណ្ឌកម្មលើកំហុសនៅក្នុងកិច្ចនីតិវិធីណាមួយ ដែលម្ចាស់ពាក្យសុំអាចជួសជុលបានដោយងាយស្រួលនោះឡើយ"[១១] ហើយសាលាក្ដីអន្តរជាតិ បានបដិសេធមិនដកចេញភស្តុតាង

---

[១០] វិធាន ៤៨ និងវិធាន ៧៦ នៃវិធានផ្ទៃក្នុង។ វិធានទាំងនេះស្របគ្នាជាមួយនឹងវិធាន ២១(១)(ក) នៃវិធានផ្ទៃក្នុង ដែលបង្គាប់ឡើងថា អ.វ.ត.ក ត្រូវ "រក្សា*តុល្យភាព*រវាងសិទ្ធិរបស់ភាគី" (គូសបញ្ជាក់បន្ថែម)។

[១១] ត.យ.អ *រឿងក្ដីពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាស្ដីពីការបង្ការ និងការដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍* (Bosnia-



PRE-TRIAL CHAMBER · E.C.C.C · C.E.T.C · CHAMBRE PRÉLIMINAIRE

ដោយផ្អែកលើមូលដ្ឋាននៃកំហុសនីតិវិធី ដែលតុលាការយល់ឃើញថា ពុំមានព្យសនកម្មណាមួយដែលបណ្តាលមកពីវិការៈដែលបានលើកឡើងនេះទេ[១២]។ គោលការណ៍ដើមចមនៃការអនុវត្តនេះគឺថា ភាគីមិនគួរបាត់បង់នូវសិទ្ធិប្រើប្រាស់តុលាការ ដោយផ្អែកលើមូលដ្ឋាននៃទម្រង់នីតិវិធីឡើយ ដរាបណាវិធានការនេះមានសមាមាត្រទៅនឹងគោលបំណងដែលខ្លួនព្យាយាមស្នើសុំ[១៣] (ពោលគឺជួសជុលព្យសនកម្ម ដែលបានប៉ះពាល់ដល់ភាគី។

១១. នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ យើងពុំឃើញមានព្យសនកម្មកើតឡើងពីកំហុសនីតិវិធីដែលបានលើកឡើងឡើយ ហើយយើងក៏ពិចារណាឃើញថា ដោយពិនិត្យឃើញមានផលវិបាកលើកិច្ចស៊ើបសួរការបដិសេធការដាក់សំណើពុំមានលក្ខណៈសមហេតុផលឡើយ ហើយវាជាវិធានការមួយមិនសមហេតុផល ក្នុងការឆ្លើយតបទៅនឹងកំហុសនីតិវិធី ដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញនោះ។ ជាពិសេស យើងសូមគូសបញ្ជាក់ថា តាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាអន្តរ-ជាតិ សំណើសុំបំពេញកិច្ចស៊ើបសួរចំនួន ៣ នេះ រួមមានព័ត៌មានសំខាន់ *ដែលក្នុងនោះ* រួមមាន

---

*Herzergovina ទល់នឹង ប្រទេសយូហ្គោស្លាវី)* សេចក្តីសម្រេចលើអញ្ញត្រកម្ម ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ១៩៩៦ កថាខណ្ឌ ២៦។ ដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ២៦ តុលាការយុត្តិធម៌អន្តរជាតិ (ត.យ.អ) បានអនុវត្តយ៉ាងស្របគ្នានូវការរកឃើញរបស់តុលាការជាបុព្វាធិការី គឺតុលាការអចិន្ត្រៃយ៍ ដែលបានលើកឡើងនៅក្នុង*ករណី Mavrommatis Palestine Concessions*៖

> "ទោះបីជាមូលដ្ឋាន ដែលយកមកផ្អែកលើការផ្តួចផ្តើមបណ្តឹង មានវិការៈដូចបានលើកហេតុផលខាងលើក៏ដោយ ករណីនេះមិនអាចជាហេតុផលគ្រប់គ្រាន់នៅក្នុងការច្រានចោលបណ្តឹងរបស់ម្ចាស់បណ្តឹងឡើយ។ តុលាការនេះ ដែលមាន យុត្តាធិការអន្តរជាតិ មិនចងកាតព្វកិច្ចឲ្យគោរពលើបញ្ហាទម្រង់បែបបទ ក្នុងកម្រិតនៃភាពចាំបាច់ ដូចគ្នាទៅនឹងច្បាប់ជាតិឡើយ"។

[១២] សូមមើល *រដ្ឋអាជ្ញា ទល់នឹង Brima* SCSL-04-16-PT សេចក្តីសម្រេចលើករណី Brima ស្តីពីសំណើសុំដកចេញចម្លើយសាក្សីរបស់អយ្យការ និងសំណើសុំផ្អាកការដាក់សេចក្តីថ្លែងការណ៍របស់អយ្យការ ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០៤។ *រដ្ឋអាជ្ញា ទល់នឹង Furundzija* IT-95-17/1 ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៩៨ (ដែលតុលាការ SCSL និងសាលាក្តី ICTY បានបដិសេធសំណើរបស់ក្រុមមេធាវីការពារក្តី សុំដកចេញចម្លើយសាក្សី ដោយផ្អែកលើមូលដ្ឋាននៃការខកខានរបស់អយ្យការ ក្នុងការលាតត្រដាងចម្លើយទាំងនេះ ស្របតាមវិធានជាធរមាន)។

[១៣] *តុលាការសិទ្ធិមនុស្សអឺរ៉ុប Levages Prestations Services ទល់នឹង ប្រទេសបារាំង* ពាក្យសុំលេខ ២១៩២០/៩៣ ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩៦ កថាខណ្ឌ ៤០ កថាខណ្ឌ ៤២ (យោបល់ចៅក្រមភាគច្រើន) និងកថាខណ្ឌ ២ និងកថាខណ្ឌ ៤ នៃមតិជំទាស់។ សូមមើលផងដែរ *រដ្ឋអាជ្ញា ទល់នឹង Brima* SCSL-04-16-PT សេចក្តីសម្រេចលើករណី Brima ស្តីពីសំណើសុំដកចេញចម្លើយសាក្សីរបស់អយ្យការ និងសំណើសុំផ្អាកការដាក់សេចក្តីថ្លែងការណ៍របស់អយ្យការ ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០៤ កថាខណ្ឌ ២០។ នេះជាហេតុផលនៅក្នុងវិធាន ២១(១)(ក)នៃវិធានផ្ទៃក្នុង ដែលចែងថា កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ត្រូវ "រក្សា*តុល្យភាព*រវាងសិទ្ធិរបស់ភាគី"។

---

ការចូលរួមរបស់ជនសង្ស័យ ដូចមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នៅក្នុងបទល្មើសដូចបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានទាំងនេះ ដែលវាអាចពាក់ព័ន្ធឲ្យសហចៅក្រមស៊ើបអង្កេតសម្រេចថាតើជនសង្ស័យទាំងនេះស្ថិតនៅក្រោមយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ដែរឬទេ។ បញ្ហាយុត្តាធិការនេះ ត្រូវបានសហចៅក្រមស៊ើបអង្កេតលើកឡើងថា ជាបញ្ហាអាទិភាព យោងតាមវិធាន ៥៥(១)នៃវិធានផ្ទៃក្នុង[១៤] និងមាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[១៥]។ សំណើសុំពន្យារពេលកំណត់ បានលើកឡើងនូវបញ្ហាសំខាន់ស្តីពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានការជូនដំណឹងអំពីកិច្ចដំណើរការនីតិវិធី នៅក្នុងសំណុំរឿងលេខ ០០៣ ដូចមានចែងនៅក្នុងវិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង ព្រមទាំងលទ្ធភាពរបស់ជនរងគ្រោះ នៅក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន អនុលោមតាមវិធានផ្ទៃក្នុង នៅក្នុងសំណុំរឿង ០០៣ ជាពិសេស សិទ្ធិតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ និងសិទ្ធិចូលរួមនៅក្នុងកិច្ចស៊ើបសួរ[១៦]។ យើងមិនអាចយល់បានថាតើសហចៅក្រមស៊ើបអង្កេត សង្ឃឹមថានឹងផ្តល់យុត្តិធម៌ដោយរបៀបណា នៅក្នុងសេចក្តីសម្រេចដែលមានសំអាងហេតុ និងមិនលម្អៀងបែបនេះ ដែលនៅក្នុងសេចក្តីសម្រេចនេះ សហចៅក្រមស៊ើបអង្កេតបដិសេធមិនចូលរួមនៅក្នុងកិច្ចស៊ើបសួរ ដែលបានផ្តួចផ្តើមឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ និងជនដែលទំនងជាជនរងគ្រោះ ហើយសហចៅក្រមស៊ើបអង្កេតបានដឹងបន្ថែមទៀតថា ព័ត៌មានស្តីពីបញ្ហាយុត្តាធិការបុគ្គល ពិតជាមានមែន ប៉ុន្តែសហចៅក្រមស៊ើបអង្កេតបានដកចេញពីក្នុងសំណុំរឿងដោយផ្ទាល់ និងយ៉ាងមានប្រសិទ្ធភាព។

## II- ភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍៖

១២. ចំពោះភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះវិញ យើងកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិ បានចុះក្នុងសំណុំឯកសារ ដោយប្រុងប្រយ័ត្ន អំពីការថ្លែងយោបល់របស់ខ្លួននៅមុន

---

[១៤] វិធាន ៥៥(១) នៃវិធានផ្ទៃក្នុងចែងថា៖ "ការស៊ើបសួរត្រូវតែធ្វើដោយខានពុំបានចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"។

[១៥] *សូមមើល* ដីកាសម្រេចស្តីអំពីការដាក់សាជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រ ៥។

[១៦] សម្រាប់ការពិភាក្សាលម្អិតលើបញ្ហានេះ សូមមើលមតិទស្សនៈរបស់ចៅក្រម Lahuis និងចៅក្រម Downing ដែលបានដាក់ភ្ជាប់មកជាមួយនឹងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert Hamil ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១ D11/2/4/4 កថាខណ្ឌ ៥។

ពេលដាក់បណ្តឹងឧទ្ធរណ៍ ដើម្បីបំពេញទៅតាមលក្ខខណ្ឌ ដូចបានកំណត់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដែលត្រូវបានជំទាស់ ហើយសហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញជំហររបស់ខ្លួនម្តងហើយម្តងទៀតថា ការចុះក្នុងសំណុំឯកសារនេះពុំចាំបាច់ធ្វើឡើងឡើយ។ បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ក្នុងរយៈពេល ៣០ ថ្ងៃ មុនពេលការខ្វែងយោបល់គ្នាដែលបានចុះក្នុងសំណុំឯកសារបានផុតរលត់[១៧]។ យើងពិចារណាឃើញថា ការចុះក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នាដោយសហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើឡើងក្រោមការតវ៉ារបស់ខ្លួន ហើយ ដូចមានសំអាងហេតុរៀបរាប់ខាងលើ យើងឯកភាពជាមួយនឹងសហព្រះរាជអាជ្ញាអន្តរជាតិថា ការចុះក្នុងសំណុំឯកសារពុំមែនចាំបាច់ត្រូវធ្វើនោះទេ។ នៅក្នុងកាលៈទេសៈទាំងនេះ យើងយល់ឃើញថា វាមានភាពសមហេតុផល ពុំចាំបាច់ចុះក្នុងសំណុំឯកសារនៃការខ្វែងយោបល់គ្នានោះទេ ហើយយើងឯកភាពជាមួយនឹងការតវ៉ារបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ ដូច្នេះ យើងយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះបានដាក់ត្រឹមត្រូវ ហើយអាចទទួលយកបាន។

**ភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១**

**ចៅក្រម Rowan DOWNING** **ចៅក្រម Katinka LAHUIS**

[១៧] វិធាន ៧១(៣) នៃវិធានផ្ទៃក្នុង។